ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៣៨៦
ចុះថ្ងៃទី១២-១២-២០១៦
សាលដីកា
លេខ : ៦៩ ក្រIV "វ"
ចុះថ្ងៃទី ២៨-០៩-២០១៧

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក **យឹម និទា**

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ១៣៨៦ ចុះថ្ងៃទី១២-១២-២០១៦ ដែលមាន ៖

១-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិចិន កើតនៅប្រទេសចិន កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងភូមិព្រែកតាជ័រ ឃុំស្វាយ ស្រុកស្អាង ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] "វ" មានកូន ០២នាក់ ជានីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការគ្មាន ។ (ក្រៅឃុំ)





Scanned by CamScanner

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៣៥ ត.ព្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ៖ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

២-ឈ្មោះ [redacted] (DAI XIAO HUI) ភេទប្រុស អាយុ៣៥ឆ្នាំ (១៩៨០) ជនជាតិចិន កើតនៅប្រទេសចិន កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរឃាមផ្ទះ ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០៣នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] រ" ទោសពីមុនគ្មាន ជាទីតិជន ។

ឃុំខ្លួននៅ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៥៦៤ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

៣-ឈ្មោះ [redacted] XUE WU TONG) ភេទប្រុស អាយុ៤៦ឆ្នាំ (០២-០៧-១៩៦៩) ជនជាតិចិន កើតនៅប្រទេសចិន សាសនាគ្មាន ទីលំនៅបច្ចុប្បន្នផ្ទះលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរឃាមផ្ទះ ប្រពន្ធឈ្មោះ [redacted] រ" មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] ស" ម្តាយឈ្មោះ [redacted] "ស" ទោសពីមុនគ្មាន ជាទីតិជន ។

ឃុំខ្លួននៅ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៥៦៣ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

៤-ឈ្មោះ [redacted] (LI XI HUA) ភេទប្រុស អាយុ៥៩ឆ្នាំ (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៥៦)ជនជាតិចិន កើតនៅប្រទេសចិនដីគោក កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួល



Scanned by CamScanner

ស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរបុគ្គលិក NAGAWORLD ប្រពន្ធឈ្មោះ[redacted] "រ" មានកូន ០១នាក់ ឪពុកឈ្មោះ[redacted]ប" ម្តាយឈ្មោះ [redacted]ស" ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួននៅ (ម១) តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥៦២ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

៥-ឈ្មោះ [redacted] (XU CHENG) ភេទប្រុស អាយុ៤១ឆ្នាំ (២៧-១០-១៩៧៥) ជនជាតិចិន កើតនៅប្រទេសចិន (ខេត្តជាងស៊ូ) សាសនាគ្មាន លំនៅបច្ចុប្បន្នផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរនាំភ្ញៀវលេងល្បែង ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០១ នាក់ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]"រ" ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួននៅ (ម១) តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥៦៧ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

មានលោកមេធា[redacted] ជាមេធាវីការពារសិទ្ធិ ។

៦-ឈ្មោះ[redacted](WANG JIE) ភេទប្រុស អាយុ៣៥ឆ្នាំ (០៨-០៩-១៩៨០)ជនជាតិចិន កើតនៅប្រទេសចិនដីគោក ខេត្តហ៊ើណាន កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរទទួលភ្ញៀវនៅ NAGAWORLD ប្រពន្ធឈ្មោះ[redacted]"រ" មានកូន ០១ នាក់ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted]"រ" ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួននៅ (ម១) តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥៦៥ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

មានលោកមេធា[redacted]មេធាវីការពារសិទ្ធិ ។

៧-ឈ្មោះ[redacted]ZHANG ZHONG SHENG) ភេទប្រុស អាយុ៤១ឆ្នាំ (១៩៧៣) ជនជាតិចិន កើតនៅប្រទេសចិន កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ០២ ផ្លូវលេខ ០២ បុរីពិភពថ្មី សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted]រ" មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ[redacted]"ស" ទោសពីមុនគ្មាន ជានីតិជន ។



Scanned by CamScanner

ឃុំខ្លួនទៅ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៥៦៦ ត.ព្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ៖ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ និង ២៩ នៃក្រមព្រហ្មទណ្ឌ ។

**ជនរងគ្រោះ**

-ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៣ឆ្នាំ ជនជាតិចិនដីគោក មានទីលំនៅបច្ចុប្បន្នស្នាក់នៅក្រុមហ៊ុនកៅអី ផ្លូវលេខ ២១ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-ឈ្មោះ [redacted] (JIANG YUN) ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន មានទីលំនៅបច្ចុប្បន្នផ្ទះជួលលេខ ៦៧E1 ផ្លូវលេខ ១៩២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ឯករឿងហេតុមានដូចតទៅ ៖**

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ កំលាំងជំនាញការិយាល័យបទល្មើសជួញដូរមនុស្សនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានទទួលបណ្តឹងរបស់ឈ្មោះ [redacted] ភេទស្រី អាយុ៣២ឆ្នាំ បានប្តឹងពីករណីបាត់ប្តី ឈ្មោះ [redacted] (JIANG YUN) ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិនដីគោក ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងរួចមកកំលាំងជំនាញធ្វើការស្រាវជ្រាវ និងចុះឆែកឆេរលំនៅដ្ឋានផ្ទះលេខ ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានភ្នំពេញ ក៏ប្រទះឃើញជនរងគ្រោះ ឈ្មោ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ត្រូវបានបង្ខាំងទុកតាំងពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដោយមានជនជាប់ចោទ [redacted] និងឈ្មោ [redacted] ជាអ្នកយាមឃ្លាំមើល ។ បន្ទាប់ពីធ្វើការសាកសួរលើឈ្មោះ [redacted] និងឈ្មោះ [redacted] រួចមក បានឱ្យដឹងថាឈ្មោះ [redacted] ហៅ [redacted] ជាអ្នកបញ្ជាឱ្យពួកខ្លួនយាមឃ្លាំមើល និងមានឈ្មោ [redacted] ហៅ LUI SIMON [redacted] ជាចៅកែរបស់ពួកខ្លួន ។ តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា មុនពេលគេបង្ខាំងរូបខ្លួននៅផ្ទះលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ គេ



Scanned by CamScanner

បានបង្ខាំងខ្លួនទៅក្នុងផ្ទះម៉ុទួលស្វាយព្រៃ១ ទើបនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ កំលាំងជំនាញបានធ្វើការស្រាវជ្រាវ ចុះទៅឆែកឆេរលំនៅដ្ឋានផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តឃាត់ខ្លួនបានជនជាប់ចោទបីនាក់ទៀតឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ៤១ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ដែលពាក់ព័ន្ធនឹងការចាប់បង្ខាំងមនុស្ស ។ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ កំលាំងជំនាញបានបន្ត ចុះឆែកឆេរផ្ទះលេខ ២ ផ្លូវលេខ២ បុរីពិភពថ្មី សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឃាត់ខ្លួនបានជនជាប់ចោទម្នាក់ទៀត ឈ្មោះ [redacted] ភេទប្រុស អាយុ៤១ឆ្នាំ កំពុងស្នាក់នៅក្នុងផ្ទះខាងលើ ហើយ ឈ្មោះ [redacted] ហៅ [redacted] ដែលជាអ្នកជួលផ្ទះខាងលើស្នាក់នៅនោះ បានរត់គេចខ្លួនបាត់ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៥១៨ "តក្រ៥" ចុះថ្ងៃទី០៣-១១-២០១៦ ដែលមានខ្លឹមសារ សម្រេចសេចក្ដីដូចខាងក្រោម៖

១-ឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ៤១ឆ្នាំ (១៩៧៣) ជនជាតិចិន រួចខ្លួនពីបទចោទប្រកាន់ពីបទ ៖ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះ លេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែ សីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៩ និង ២៥៤ និងមាត្រា ៣៥០ នៃក្រមនីតិវិធី ក្រមព្រហ្មទណ្ឌ ។

២-ផ្ដន្ទាទោសជនជាប់ចោទ៖

ក.ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិចិន

ដាក់ពន្ធនាគារកំណត់រយៈពេល ២៥ (ម្ភៃប្រាំ) ឆ្នាំ ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មាន ស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានី

Scanned by CamScanner

ភ្នំពេញ និងផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន

គ.ឈ្មោះ [redacted] ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិចិន

ឃ.ឈ្មោះ [redacted] ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិចិន

ង.ឈ្មោះ [redacted] ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិចិន

ច.ឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន

ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទ ៖ **សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ និង ២៨ នៃក្រមព្រហ្មទណ្ឌ ។

៣-បង្គាប់ឱ្យចេញដីកាចាប់-ឃុំខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ មកផ្តន្ទាទោសតាមអំណាចសាលក្រមនេះ ។

៤-វត្ថុចាប់យកមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៧ វ.ត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៦ របស់ឃ្លាំងតម្កល់វត្ថុចាប់យកសាលាដំបូងរាជធានីភ្នំពេញ រួចមាន ៖

-លិខិតឆ្លងដែនចំនួន ០៩ ច្បាប់ (ចិន០៦ ច្បាប់, ខ្មែរ ០១ ច្បាប់ ,វៀតណាម ១ច្បាប់ និងកូរ៉េ ០១ច្បាប់ ) ។

-អត្តសញ្ញាប័ណ្ណចំនួន០៥ (ចិន០៤ ច្បាប់ ,ខ្មែរ ០១ច្បាប់)

-ទូរស័ព្ទដៃចំនួន០៨គ្រឿង (ជាក់ស្តែង ០៧គ្រឿង៖ ទូរស័ព្ទSAM SUNG ០២គ្រឿង, NOKIA ០២ គ្រឿង ,Iphone ០២គ្រឿង ,APPO ០១គ្រឿង ។

-នាឡិកាដៃចំនួន ៣គ្រឿង (បែកកញ្ចក់ចំនួន ១គ្រឿង) ខ្សែក ០២ ខ្សែ ,ផ្លាករូបព្រះពណ៌មាសចំនួន ០១ ។

-កាតគ្រីឡានចំនួន ០២ (ថតចម្លង០១) និងIpad ចំនួន ០១ (A1474) ។



Scanned by CamScanner

សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ ខែសីហាឆ្នាំ២០១៦ ,និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] បានប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ៥១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ត្រង់ចំណុចទី២ "ក" ចំណុចទី០៣ និងចំណុចទី៣ និងចំណុចទី ០៤ នៃសេចក្តីសម្រេច ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មេធាវី [redacted] និងមេធាវី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted], [redacted], [redacted] បានប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ៥១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ត្រង់ចំណុចទី២ នៃសាលក្រម ។

**បានឃើញ** របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៩-០៦-២០១៧ ។

**បានឃើញ** សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២០-០៧-២០១៧ ។

**នាពេលសវនាការ**

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ៖ ខ្លួនមកប្រទេសកម្ពុជានៅឆ្នាំ២០១៥ ខែ មិថុនា ថ្ងៃទី២៥ គឺខ្លួនមកដើរខោអាវនៅរោងចក្រតាខ្មៅ ថៅកែបានប្រាប់មកមិត្តភក្តិធ្វើការរោងចក្រឈ្មោះ [redacted] ។ ពេលកំពុងហូបបាយ ស្រាប់តែគេមកចាប់តែម្តង នៅផ្ទះនោះមានបុគ្គលិកច្រើននាក់ បុគ្គលិកដេរខោអាវមានឈ្មោះ ខ្មែរតែអត់ស្គាល់ឈ្មោះ ។ ខ្លួនមិនដែលធ្លាប់ទៅណាហ្នាទេ ។ សូមអោយលោកចៅក្រមជួយបន្ធូបន្ថយទោស។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នៅសាលាដំបូងរាជធានីភ្នំពេញថា ៖ ខ្លួនបានមកដល់ប្រទេសកម្ពុជានៅក្នុងខែ មិថុនា ឆ្នាំ២០១៥ មកដើម្បីរកការងារធ្វើ ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥



Scanned by CamScanner

ខ្លួនបានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន **សាមិនជឹងយ៉ុង** មានទីតាំងនៅក្នុងNAGAWORD បន្ទប់លេខ ១២៦៩ ជាន់ទី ១២ ហើយតួនាទីរបស់ខ្លួនគឺដើររកភ្ញៀវឲ្យមកលេងល្បែង ។ អ្នកគ្រប់គ្រងនៅទីនោះឈ្មោះ [redacted]ព្រមទាំងបេឡាម្នាក់ជាមនុស្សស្រី ។ ក្រោយពីឈប់ធ្វើការងារខាងលើ ក៏ប្តូរទីយាមផ្ទះឲ្យឈ្មោះ [redacted]ញ ហើយឈ្មោះ[redacted]នះជាអ្នកដើរទាលុយគេជាមួយប៉ូលីសខ្មែរម្នាក់ ។ ផ្ទះដែលខ្លួនយាមនៅម្តុំទួលស្វាយព្រៃ ជាផ្ទះរបស់ឈ្មោះ[redacted]និងប្រពន្ធ ជាអ្នកជួល ហើយខ្លួន និងឈ្មោះ [redacted]ជាអ្នកយាមផ្ទះនោះមិនឲ្យអ្នកណាចេញចូលក្រៅពីឈ្មោះ[redacted]ងប្រពន្ធទេ ។

-ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា ៖ ខ្លួនមកដល់ស្រុកខ្មែរកាលពីឆ្នាំ២០១៦ ខ្លួនមានគោលបំណងធ្វើការដេរខោអាវនៅក្នុងរោងចក្រ ឆ្នាំ២០១៥ ខែវិច្ឆិកា ខ្លួនធ្លាប់ទៅណាហ្គាសធ្វើការឲ្យថៅកែរកភ្ញៀវ ហើយខ្លួនបានរកភ្ញៀវ ដែលចង់រកខ្ចីលុយ ខ្លួនធ្លាប់ទៅចាក់អង្រែ កន្លែងស្នាក់នៅ មានជនរងគ្រោះបង្ខាំងមនុស្សទុកនៅទីនោះទេ ។ ឈ្មោះ[redacted]ានជំពាក់លុយកាស៊ីណូ គេឲ្យឈ្មោ[redacted]ញចូលបាន ។ ឈ្មោះ[redacted]ជាអ្នកនាំខ្លួនឲ្យចូលធ្វើការ ហើយឈ្មោះ[redacted]មិនមែនជាថៅកែទេ ឈ្មោ[redacted] ជាអ្នកហៅម៉ូយ ។ ខ្លួនអត់ដែលនាំភ្ញៀវទេ ។ សុំអោយលោកចៅក្រមអោយខ្លួនបានរួចផុតពីបទចោទ ។

-ជនជាប់ចោ[redacted]បានឆ្លើយថា ៖ មកធ្វើការទាក់ទងដេរខោអាវ ក្រោយមកខ្លួនឈប់ធ្វើការដេរខោអាវ ហើយនាំគាត់ទៅធ្វើការនៅណាហ្គាវើល ខ្លួនជាអ្នករកភ្ញៀវ ឲ្យខ្ចីលុយពីឈ្មោះ [redacted]និងឈ្មោះ[redacted] មួយខែខ្លួនបាន ៣០០ ដុល្លាអាមេរិក ។ ផ្ទះរបស់ខ្លួនមានគ្នា ៤ ទៅ ៥នាក់ ជាមួយឈ្មោ[redacted] [redacted]នៅកន្លែងស្នាក់នៅក៏ពុំមានមនុស្សដែលត្រូវគេបង្ខាំងទុកទេ ។ សុំឲ្យក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ ។ សុំអោយលោកចៅក្រមអោយខ្លួនបានរួចផុតពីបទចោទ ។

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ៖ ខ្លួនមកប្រទេសកម្ពុជានៅឆ្នាំ២០១៥ ខែឧសភា ថ្ងៃទី២២ មកធ្វើការរកភ្ញៀវនៅណាហ្គា ខ្លួនគ្រាន់តែណែនាំឲ្យឈ្មោ[redacted]អ្នកនាំភ្ញៀវទៅលេងល្បែង ឬខ្ចីលុយគឺខ្លួនមិនដឹង ខ្លួននៅជាមួយឈ្មោះ[redacted]និងឈ្មោះ [redacted]ជាបេឡា ។ ខ្លួនបាន មួយខែ ៣០០ ដុល្លាអាមេរិក ខ្លួនចេញទៅធ្វើការម៉ោង ៣ ល្ងាច ម៉ោង ៥ ព្រឹក ទើបត្រឡប់វិញ ។ ខ្លួនអត់ស្គាល់ឈ្មោះ[redacted]ទ ។ សុំឲ្យក្រុមប្រឹក្សាលើកលេងចោទប្រកាន់ ។ សុំលោកចៅក្រមជួយលើកលែងទោស ។



Scanned by CamScanner

-មេធា[redacted]បានសួរទៅ[redacted]ថា៖ ខ្លួនស្គាល់ឈ្មោះ[redacted] នៅឯណាហ្គាវើល ជាង់ទី ១ ឬជាន់ទី ៤ ។ ខ្លួនមានតួនាទី គឺខ្លួនអ្នកមើលភ្លៀងឲ្យអ[redacted]ខ្លួនអត់ស្គាល់ឈ្មោះ[redacted] , [redacted]ខ្លួនអត់ស្គាល់ទេ ។ មុនពេលឃាត់ខ្លួន ខ្លួនមកធ្វើការរោងចក្រប្រហែល ៦ ខែ ហើយខ្លួនស្នាក់នៅទូតចិន នៅជាន់ទី ២ ។

-មេធាវី[redacted]បានសន្និដ្ឋានថា៖ កូនក្តីខ្លួនមិនបានសម្រួល សុំអោយក្រុមប្រឹក្សាពិចារណារួចផុតពីបទចោទ។

-មេធា[redacted]បានសន្និដ្ឋានថា៖ សុំលោកប្រធានក្រុមប្រឹក្សាសំរេចឱ្យរួចផុតពីបទចោទ។

-មេធាវី [redacted]បានសន្និដ្ឋានថា៖ សុំឱ្យក្រុមប្រឹក្សាពិចារណាសម្រេចបន្ធូបន្ថយទោស ។

-មេធាវី[redacted]បានសន្និដ្ឋានថា៖ សុំលោកប្រធានសម្រេចអោយកូនក្តីខ្ញុំបាទ រួចផុតពីបទចោទ

-តំណាងមហាអយ្យការបានសន្និដ្ឋានថា ៖ ក្រោយពីសាកសួរដេញដោល ឃើញថាជនជាប់ចោទបានឆ្លើយដូចគ្នា ជាមួយជនរងគ្រោះ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមទុកជាបានការដដែល ។

-ក្រោយពីស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណាចចម្លើយជនជាប់ចោទ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ[redacted]ហៅ[redacted] បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ត្រង់ចំណុចទី២ "ក" ចំណុចទី០៣ និងចំណុចទី៣ និងចំណុចទី ០៤ នៃសេចក្តីសម្រេច ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned by CamScanner

-ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មេធាវី[redacted]និងមេធាវី[redacted] ទទួលសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ដោយជនជាប់ចោទឈ្មោះ[redacted], [redacted](LI XI HUA), [redacted] និងឈ្មោះ[redacted]ទប្ដឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ៩១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ត្រង់ចំណុចទី២ នៃសាលក្រម ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍អាច ទទួលជំនុំ ជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា ៖ ខ្លួនមកប្រទេសកម្ពុជានៅឆ្នាំ២០១៥ ខែ មិថុនា ថ្ងៃទី ២៥ គឺខ្លួនមកដេរខោអាវនៅរោងចក្រតាខ្មៅ ថៅកែបានប្រាប់មកមិត្តភក្តិធ្វើការរោងចក្រឈ្មោះ[redacted] ពេលកំពុងហូបបាយ ស្រាប់តែគេមកចាប់តែម្ដង នៅផ្ទះនោះមានបុគ្គលិកច្រើននាក់ បុគ្គលិកដេរខោអាវមាន ឈ្មោះខ្មែរតែអត់ស្គាល់ឈ្មោះ ។ ខ្លួនមិនដែលធ្លាប់ទៅណាហ្គាទេ ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នៅដំណាក់កាលសាលាដំបូងរាជធានី ភ្នំពេញថា ៖ ខ្លួនបានមកដល់ប្រទេសកម្ពុជានៅក្នុងខែ មិថុនា ឆ្នាំ២០១៥ មកដើម្បីរកការងារធ្វើ ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥ ខ្លួនបានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន **សាមិនជីងយ៉ុង** មានទីតាំងនៅក្នុង NAGAWORD បន្ទប់លេខ ១២៦៩ ជាន់ទី ១២ ហើយតួនាទីរបស់ខ្លួនគឺដើររកភ្ញៀវឱ្យមកលេងល្បែង ។ អ្នកគ្រប់គ្រង នៅទីនោះឈ្មោះ[redacted]និងឈ្មោះ[redacted]ព្រមទាំងបេឡាម្នាក់ជាមនុស្សស្រី ។ ក្រោយពីឈប់ធ្វើការងារខាងលើ ក៏ប្ដូរទីយាមផ្ទះឱ្យឈ្មោះ [redacted] វិញ ហើយឈ្មោះ [redacted] នេះជាអ្នកដើរទាលុយគេជាមួយប៉ូលីសខ្មែរម្នាក់ ។ ផ្ទះដែលខ្លួនយាមនៅម្ដុំទួលស្វាយព្រៃ ជាផ្ទះរបស់ឈ្មោះ[redacted]និងប្រពន្ធ ជាអ្នកជួល ហើយខ្លួន និងឈ្មោះ[redacted] ជាអ្នកយាមផ្ទះនោះមិនឱ្យអ្នកណាចេញចូលក្រៅពីឈ្មោះ[redacted]និងប្រពន្ធទេ ។

-មេធ[redacted]ានសន្និដ្ឋានថា៖ សុំឱ្យក្រុមប្រឹក្សាពិចារណាសម្រេចបន្ធូរបន្ថយទោស ។

-ក្រុមប្រឹក្សាយល់ឃើញថា៖ តាមចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ នៅដំណាក់កាលអយ្យការ អមសាលាដំបូង និងនាពេលសវនាការនេះ មិនមានភស្តុតាងច្បាស់លាស់ណាមួយ អាចអោយក្រុមប្រឹក្សាជឿជាក់ បានឡើយ ។ តាមចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលអយ្យការសាលាដំបូងថា: នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ[redacted]ានប្ដូរខ្ញុំ និងឈ្មោះ[redacted]ទៅយាមផ្ទះនៅម្ដុំចាក់អង្រែនោះ ខ្ញុំបានឃើញជនរងគ្រោះ ឈ្មោះ[redacted]ភេទប្រុស [redacted]ត្រូវបានគេទុកនៅក្នុងផ្ទះនោះ ក្នុងបន្ទប់ជាន់ទី៣ ហើយប្រហែលជាពីរ-បី ថ្ងៃក្រោយ ក៏មានជនជាតិចិនពីរនាក់ទៀតត្រូវបានឈ្មោះ[redacted] យកមកទុកក្នុងផ្ទះជាមួយ [redacted](**ឯកសារលេខ៤**) ។

តាមចម្លើយសារភាពខាងលើនេះបានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តបទៈ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ពិតប្រាកដមែន។

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ៖ ខ្លួនមកដល់ស្រុកខ្មែរកាលពីឆ្នាំ២០១៦ ខ្លួនមានគោលបំណងធ្វើការដេរខោអាវនៅក្នុងរោងចក្រ ឆ្នាំ២០១៥ ខែវិច្ឆិកា ខ្លួនធ្លាប់ទៅណាហ្គាសធ្វើការឱ្យថៅកែរកភ្ញៀវ ហើយខ្លួនបានរកភ្ញៀវដែលចង់រកខ្ចីលុយ ខ្លួនធ្លាប់ទៅចាក់អង្រែ កន្លែងស្នាក់នៅ មានជនរងគ្រោះបង្ខាំងមនុស្សទុក្ខនៅទីនោះទេ ។ ឈ្មោះ[redacted]បានជំពាក់លុយកាស៊ីណូ គេឱ្យឈ្មោះ[redacted]ញចូលបាន ។ ឈ្មោះ[redacted]ជាអ្នកនាំខ្លួនឱ្យចូលធ្វើការ ហើយឈ្មោះ[redacted]មិនមែនជាថៅកែទេ ឈ្មោះ [redacted] ជាអ្នកហៅម៉ូយ ។ ខ្លួនអត់ដែលនាំភ្ញៀវទេ ។ សុំអោយលោកចៅក្រមអោយខ្លួនបានរួចផុតពីបទចោទ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរថាៈ ខ្ញុំមិនដឹងថាគោលការណ៍របស់ក្រុមហ៊ុន ត្រូវចាប់បង្ខាំងមនុស្សដើម្បីទាមទារប្រាក់នោះទេ។ ខ្ញុំសូមបញ្ជាក់ថា មុនរយៈពេល ២ខែនៃថ្ងៃមុនបង្ក្រាបគឺ ខ្ញុំដឹងថាក្រុមហ៊ុនបានចាប់បង្ខាំងមនុស្សប្រុសម្នាក់ទៀត [redacted]ភេទប្រុស ជនជាតិចិន ។ សរុបមកគឺខ្ញុំដឹងថាមានការបង្ខាំងចំនួន ២នាក់ **(ឯកសារលេខ១៦)** ។ តាមចម្លើយសារភាពនៅដំណាក់កាលអយ្យការថាៈ ពេលខ្ញុំបាទមកដល់ ខ្ញុំបានឃើញឈ្មោះ[redacted]នៅក្នុងផ្ទះនេះរួចទៅហើយ [redacted] ប្រាប់ថា គាត់ជំពាក់លុយក្រុមហ៊ុនជាង ១ ម៉ឺនដុល្លា ទើបគេនាំគាត់មកទីនេះ ។ ពេលខ្ញុំចេញក្រៅជាមួយ[redacted] គឺឈ្មោះ [redacted]ជាអ្នកយាមឈ្មោះ[redacted]ហើយបើឈ្មោះ[redacted]ចេញក្រៅ គឺខ្ញុំបាទជាអ្នកយាមឈ្មោះ [redacted] ក្រោយមកទៀតនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ [redacted]និងឈ្មោះ [redacted] បាននាំ ជនជាតិម្នាក់ទៀត ឈ្មោះ[redacted]មកឃុំទុកនៅជាន់ទី៣ **(ឯកសារលេខ១២)** ។

-មេធាវី [redacted]បានសន្និដ្ឋានថា៖ កូនក្តីខ្លួនមិនបានសម្រួល សុំអោយក្រុមប្រឹក្សាពិចារណា រួចផុតពីបទចោទ។

-ក្រុមប្រឹក្សាយល់ឃើញថាៈ ជនជាប់ចោទ ព្រមទាំងមេធាវីការសិទ្ធិអោយជនជាប់ចោទ មិនមានភស្តុតាងណាមួយលើកមកបញ្ជាក់ អាចអោយក្រុមប្រឹក្សាជឿជាក់បានឡើយ ។ តាមចម្លើយសារភាពនៅដំណាក់កាល អយ្យការ, ដំណាក់កាល ចៅក្រម ស៊ើបសួរ ពិតជាមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់ថា ជនជាប់



Scanned by CamScanner

ចោទពិតជាបានប្រព្រឹត្តបទ៖ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ពិតប្រាកដមែន ។

-ជនជាប់ចោ[redacted]នឆ្លើយថា ៖ មកធ្វើការទាក់ទងដេរខោអាវ ក្រោយមកខ្លួនឈប់ធ្វើការដេរខោអាវ ហើយនាំគាត់ទៅធ្វើការនៅណាហ្គាវើល ខ្លួនជាអ្នករកភ្ញៀវ ឱ្យខ្ចីលុយពីឈ្មោ[redacted]និងឈ្មោះ[redacted] មួយខែខ្លួនបាន ៣០០ ដុល្លារអាមេរិក ។ ផ្ទះរបស់ខ្លួនមានគ្នា ៤ ទៅ ៥នាក់ ជាមួយឈ្មោះ [redacted] [redacted]កន្លែងស្នាក់នៅក៏ពុំមានមនុស្សដែលត្រូវគេបង្ខាំងទុកទេ ។ សុំឱ្យក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ ។ សុំអោយលោកចៅក្រមអោយខ្លួនបានរួចផុតពីបទចោទ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្ញុំរស់នៅផ្ទះនៅសង្កាត់ទួលស្វាយព្រៃផ្ទះលេខ១១២ ផ្លូវ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ខ្ញុំរស់នៅជាន់ទី៣ហើយគេបង្ខាំងមនុស្សនៅជាន់ទី៤ ។ ខ្ញុំឃើញគេបង្ខាំងមនុស្សតែម្នាក់គត់នៅ ជាន់នោះរយៈពេលជាង២ខែ មកហើយ គិតដល់ថ្ងៃកើតហេតុនេះ ។ ខ្ញុំមិនដឹងថានរណាជាអ្នកដែលកាន់ជាន់ទី៤ទេ ។ ខ្ញុំគ្រាន់តែដឹងថា អ្នកដែលមិនព្រមសងលុយក្រុមហ៊ុន នឹងត្រូវយកទៅដាក់បង្ខាំងនៅជាន់ទី៤នោះ (ឯកសារលេខ១៦) ។

-មេធាវី [redacted] បានសន្និដ្ឋានថា: សុំអោយកូនក្តីខ្លួនរួចផុតពីបទចោទ ។

-ក្រុមប្រឹក្សាយល់ឃើញថា: មិនមានភស្តុតាងណាមួយលើកយកមកបញ្ជាក់ ដែលអាចក្រុមប្រឹក្សាជឿជាក់បានឡើយ ។ តាមចម្លើយសារភាពនៅដំណាក់កាលចៅក្រមស៊ើបសួរ និងតាមចម្លើយឆ្លើយនាសាលាឧទ្ធរណ៍ របស់ជនជាប់ចោទបានផ្ទុះបញ្ជាំងអោយឃើញពីភាពស៊ើសង្វាក់គ្នាថា ជនជាប់ចោទឈ្មោះ [redacted] បានប្រព្រឹត្តបទ: សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ពិតប្រាកដមែន ។

-ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា ៖ ខ្លួនមកប្រទេសកម្ពុជានៅឆ្នាំ២០១៥ ខែឧសភា ថ្ងៃទី២២ មកធ្វើការរកភ្ញៀវនៅណាហ្គា ខ្លួនគ្រាន់តែណែនាំឱ្យឈ្មោ[redacted]រកនាំភ្ញៀវទៅលេងល្បែង ឬខ្ចីលុយគឺខ្លួនមិនដឹង ខ្លួននៅជាមួយឈ្មោះ[redacted]និងឈ្មោះ [redacted] ខ្លួនបាន មួយខែ ៣០០ ដុល្លារអាមេរិក ខ្លួនចេញទៅធ្វើការម៉ោង ៣ ល្ងាច ម៉ោង ៥ ព្រឹក ទើបត្រឡប់វិញ ។ ខ្លួនអត់ស្គាល់ឈ្មោ[redacted] ។ សុំឱ្យក្រុមប្រឹក្សាលើកលែងចោទប្រកាន់ ។ សុំលោកចៅក្រមជួយលើកលែងទោស ។



Scanned by CamScanner

-តាមចម្លើយសារភាពនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ក្នុងកំឡុងពេលធ្វើការរបស់ខ្ញុំ ខ្ញុំមិនដែលបានឃើញគេនាំមនុស្សមកបង្ខាំងទេ ខ្ញុំស្នាក់នៅជាន់ទី៣ ខ្ញុំគ្រាន់តែឃើញមនុស្សនៅជាន់ទី៤នោះតែប៉ុណ្ណោះ ។ ខ្ញុំគ្រាន់តែលឺគេនិយាយថាអ្នកគ្មានប្រាក់បង់សងជូនក្រុមហ៊ុន នឹងដាក់បង្ខាំងនៅជាន់ទី៤ ដើម្បីឱ្យគេទាក់ទងទៅបងប្អូនសាច់ញាតិឱ្យយកលុយមកបង់ **(ឯកសារលេខ១៦)** ។

-មេធាវី[redacted]ធ្វើការសន្និដ្ឋានថា៖ ខ្លួនស្គាល់ឈ្មោះ[redacted]នៅឯណាហ្គាវើលជាន់ទី ១ ឬជាន់ទី ៤ ។ ខ្លួនមានតួនាទី គឺខ្លួនអ្នកមើលភ្លៀង[redacted]ខ្លួនអត់ស្គាល់ឈ្មោះ[redacted]ខ្លួនអត់ស្គាល់ទេ ។ មុនពេលឃាត់ខ្លួន ខ្លួនមកធ្វើការរោងចក្រប្រហែល ៦ ខែ ហើយខ្លួនស្នាក់នៅទួតចិន នៅជាន់ទី ២ ។

-ក្រុមប្រឹក្សាយល់ឃើញថា: ជនជាប់ចោទ និងមេធាវីការពារសិទ្ធិអោយជនជាប់ចោទ មិនមានភស្តុតាងណាមួយអាចអោយក្រុមប្រឹក្សាជឿជាក់បានឡើយ ។ តាមចម្លើយរបស់ជនជាប់ចោទបានសារភាពថា ពិតជាបានដឹងថាមានការបង្ខាំងមនុស្សខុសច្បាប់មែន ។ ជនជាប់ចោទបានដឹងថាមានជនរងគ្រោះនៅជាន់ទី៤ដែលជាកន្លែងបង្ខាំងមនុស្សខុសច្បាប់ ហើយខ្លួនមិនប្តឹងរាយការណ៍ទៅសមត្ថកិច្ចទេ នេះជាអំពើជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសដោយជនជាប់ចោទ[redacted]នសម្រេច ។ តាមចម្លើយសារភាពនៅដំណាក់កាលចៅក្រមស៊ើបសួរព្រមជាមួយ និងភស្តុតាងគ្រប់គ្រាន់ បានបញ្ជាក់ឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] បានប្រព្រឹត្តបទ: សមគំនិតក្នុងអំពើ ចាប់ឃុំឃាំង និងបង្ខាំងដោយខុស ច្បាប់មានស្ថានទម្ងន់ទោស ពិតប្រាកដមែន ។

-មេធាវី[redacted]នសន្និដ្ឋានថា៖ សុំលោកប្រធានក្រុមប្រឹក្សាសំរេចឱ្យរួចផុតពីបទចោទ។

-ក្រុមប្រឹក្សាយល់ឃើញថា: ជនជាប់ចោទឈ្មោះ[redacted] មិនបានបង្ហាញខ្លួនដើម្បីលើកភស្តុតាងណាមួយអះអាង អោយក្រុមប្រឹក្សាជឿជាក់បានឡើយ ។ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនបានបង្ហាញភស្តុតាងណាមួយ ក្រៅតែពីសុំអោយលើកលែងបទចោទនោះទេ ។

២-ក្រុមប្រឹក្សាយល់ឃើញថា: ជនជាប់ចោទឈ្មោះ[redacted]

ពិតជា បានប្រព្រឹត្តបទ៖ **សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ១១២



Scanned by CamScanner

EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ និង ២៩ នៃក្រមព្រហ្មទណ្ឌ ។

-ក្រុមប្រឹក្សាយល់ឃើញថា: ជនជាប់ចោទឈ្មោ[redacted]ពិតជាបានប្រព្រឹត្តបទ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ៤២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ១១២ EH ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ ។

៣-តំណាងមហាអយ្យការធ្វើការសន្និដ្ឋានថា: ក្រោយពីសាកសួរដេញដោល ឃើញថាជនជាប់ចោទបានឆ្លើយ ដូចគ្នាជាមួយជនរងគ្រោះ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមទុកជាបានការដដែល ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ៤១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញសម្រេចមកមានលក្ខណៈត្រឹមត្រូវ គប្បីតម្កល់ទុកជាបានការ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោ[redacted]ហៅ [redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មេធាវី [redacted]និងមេធាវី[redacted] ទទួលសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ដោយជនជាប់ចោទឈ្មោះ[redacted], [redacted] (LI XI HUA), [redacted]និង ឈ្មោ[redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤១៨ "ត" ក្រ៥ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែរ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។



Scanned by CamScanner

សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១៧-០៨-២០១៧ ចំពោះមុខជនជាប់ចោទ [redacted]

និង ឈ្មោះ [redacted] កំបាំងមុខឈ្មោះ [redacted] ចំពោះមុខមេធាវីការពារសិទ្ធិនៃជនជាប់ចោទទាំងអស់

និង ប្រកាសជាសាធារណៈ ថ្ងៃទី២៨-០៩-២០១៧ ។ បើសិទ្ធិឲ្យប្ដឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| | *រាជធានីភ្នំពេញ*, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៧ |
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned by CamScanner